# វចនានុក្រម ពេទ្យ
# អង់គ្លេស – ខ្មែរ

# ENGLISH – KHMER
# MEDICAL DICTIONARY

ដោយ : ហែម-សារី

BY: SARY HEM

**A. C.** មុនពេលអាហារ

**abcess** បូស, ដំបៅ

**abdomen** ពោះ

**abdominal** នៃពោះ

**abdominal paracentesis** ការបូមទឹកចេញពីពោះ

**abdominous** ដែលរីកធំ, ដែលដុះពោះចង្កេះរៀវ

**abnormal** ខុសពីធម្មតា

**abortion** ការពន្លូតកូន, ការមិនបានសំរេចបំណង

**absorb** ស្រូប, បឺត, ជ្រាប

**acetabulum** ប្រហោងសន្លាក់ឆ្អឹងត្រគាក

**ache** ឈឺ, ឈឺអួចៗ

**acid** អាស៊ីដ, ទឹកក្រូត, សារធាតុជូរ

**acidosis** ការមានជាតិអាស៊ីដច្រើនពេកនៅក្នុងខ្លួន

**acne** មុន (រោគសើស្បែកមុខ)

**activate** ធ្វើឲ្យសកម្ម

**acute** ធ្ងន់, ខ្លាំង (ជម្ងឺ)

**addict** ញៀន

**addiction** ការញៀន

**adenitis** ការហើមរលាកគ្រន្ថី

**adenoid** ដុំសាច់ដុះនៅក្នុងប្រហោងច្រមុះ

**adenoids** ជំងឺដុះសាច់ក្នុងច្រមុះ ឬក្នុងបំពង់ក

**adenoma** សាច់ពកម្យ៉ាងដែលដុះពីក្រពេញ ឬដូចជាក្រពេញ

**adhesion** ការជាប់ផ្នែកមួយនៃខ្លួន ទៅនឹងផ្នែកមួយទៀត ខុសពីធម្មតា

**adhesive** ដែលជាប់ស្អិត, ការ

**admit** ទទួលអនុញ្ញាតឲ្យចូលមន្ទីរពេទ្យ, ការកត់សេចក្តីផ្សេងៗដែលទើបមកដេកពេទ្យ

**adolescence** តរុណវ័យ, វ័យកំឡោះក្រមុំ

**adrenal** ជំរងមូត្រ, ក្បាលវក្កគ្រន្ថី

**adrenalectomy** ការវះកាត់យកគ្រន្ថីចេញ

**adrenaline** ទឹកដែលបញ្ចេញពីគ្រន្ថី

**agitation** ការរញ្ជួយ, ការជ្រួលច្រាល់ចិត្ត

**albumin** អាណ្ឌសេត, (បារ. អាល់ប៊ូមីន)

**alcohol** អាកុល, ជាតិសុរា

**alergy** ប្រតិកម្មចំពោះវត្ថុអ្វីមួយ, ទាស់

**aliment** អាហារ, ការផ្គត់ផ្គង់ចំណី

**alimetary tract** គ្រឿងរំលាយអាហារ

**alkaline** ទាក់ទងនឹងជាតិក្បុង

**alkaloid** វត្ថុធាតុជាតិក្បុង

**alkalosis** មានជាតិក្បុងច្រើនពេក

**alleviate** សំរាល, ធ្វើឲ្យធូរស្រាល

**ambulant** ដែលអាចដើរបាន, ដែលអាចដើរទៅមកបាន

**amebiasis** រោគរាកមូល

**amenorrhea** ការរាំងរដូវ

**amiocenthesis** ការពិសោធន៍ទឹកភ្លោះ (ការបូមទឹកចេញពីពោះ មកពិនិត្យមើលអាការទារកក្នុងឧទរ)

**amnion fluid** ទឹកភ្លោះ

**amnion** ថង់ទឹកភ្លោះ

**amoeba** មេរោគរាកមូល, សត្វមានកោសិកាតែមួយ

**amputation** ការកាត់ដៃជើង ឬសរីរាង្គអ្វីមួយ

**amputee** មនុស្សកំបុតដៃ ឬជើង

**amylase** អង់ស៊ីមម្យ៉ាងនៃប្រព័ន្ធរំលាយអាហារ ដែលជួយឲ្យម្សៅធញ្ញជាតិទៅជាមានជាតិស្ករ

**amylose** ការរំលាយបដ្ឋជាតិ

**amyotonin** ការគ្មានសាច់ដុំ

**anaerobic** ការដុះលូតលាស់ដោយមិនបាច់មានខ្យល់ ឬមានអុកស៊ីហ្សែន

**anal** នៃទ្វារធំ, នៃរន្ធគូទ

**analgesia** ការស្ពឹក, ការបាត់ស្មារតី

**anaphylactic shock** ការប្រត្តិកម្មខ្លាំងដោយវត្ថុធាតុម្យ៉ាង (ដូចជាថ្នាំពេនិស៊ីលីន) ដែលអាចនាំឲ្យស្លាប់ក៏មាន

**anatomy** កាយវិភាគសាស្ត្រ

**anemia** ការស្លេកស្លាំង, កង្វះឈាមកហម

**anencephalic** ដែលគ្មានលលាដ៏និងខួរក្បាល, ដែលទាក់ទងលលាដ៏និងខួរក្បាល

**aneroxia nervosa** ការអត់ឃ្លានអាហារប្លែកពីធម្មតា ដោយព្រោះខ្លាចធាត់ ដែលបណ្តាលឲ្យស្គមស្គាំង ឬខ្វះជីវជាតិ

**anesthesia** (general) ការចាក់ថ្នាំសន្លប់ ឬសណ្តំ

**anesthesia** (local) ការធ្វើឲ្យស្ពឹក ឬសណ្តំ

**anesthetic** ថ្នាំសំរាប់ធ្វើឲ្យស្ពឹក ឬសណ្តំ

**anesthetize** ធ្វើឲ្យស្ពឹក, ធ្វើឲ្យសណ្តំ

**aneurysm** ការប៉ោងសរសៃឈាមក្រហម, ប្រដាប់ធ្វើឲ្យរាវឈាម

**angiography** ការពិនិត្យមើលសរសៃឈាម ដោយប្រើកម្មរស្មីអិក្ស

**angiology** វិទ្យាសាស្ត្រខាងសរសៃឈាម

**ankle** កជើង, ខ្នងជើង

**ankylostome** ព្រូនតូចម្យ៉ាង មានខ្លួនមូល រាងកោងដូចទំពក់ ចូលតាមស្បែក ជាពិសេសតាមបាតជើង កាលណាដើរជើងទទេ

**anoxia** ការខ្វះខ្យល់អុកស៊ីស្សែន

**antacid** ដែលគ្មានជាតិជូរ (គ្មានអាស៊ីដ)

**antepatrum** ការកើតហេតុនៅមុនពេល ឬនៅពេលសំរាលកូន

**antibiotic** បដិបក្ខប្រាណ, ដែលបង្កើតដោយសត្វ ឬរុក្ខជាតិ ជាពិសេសគឺផ្សិតឬបាក់តេរី, ដែលបង្កើតឡើងដោយសត្វឬរុក្ខជាតិ មានអំណាចប្រឆាំងនឹងរោគបាក់តេរី

**antibody** អង្គបដិបក្ខក្នុងខ្លួន ដែលមាននៅក្នុងខ្លួនស្រាប់ ឬដែលកើតឡើងក្រោយពីពេលចាក់បញ្ចូលអតិសុខុមប្រាណ ឬក៏ផលិតអតិសុខុមប្រាណ

**antifungal** ដែលបំផ្លាញផ្សិត

**antigen** ធាតុអតិសុខុមប្រាណ

**antipruritic** ការការពារ ឬការធ្វើឲ្យបាត់រមាស់, ថ្នាំបំបាត់រមាស់

**antrum** បន្ទប់ ឬផតជិតនឹងបិទ ជាពិសេសនៅក្នុងឆ្អឹង, ភាគនៃក្រពះជាប់នឹងពោះវៀនតូច

**anuria** អមូត្រភាព (ការដែលវក្កមិនបញ្ចេញទឹកនោម, ឬការទល់នោម)

**anus** ទ្វារធំ, ទ្វារលាមក

**aorta** សរសៃឈាមក្រហមធំកោង

**apex beat** ស្ទូរចលនាបេះដូងនៅចុងដង្ហើម

**apparatus** គ្រឿងឧបករណ៍

**appendectomy** ការវះកាត់យកខ្នែងពោះវៀន

**appendix** ខ្នែងពោះវៀន

**appetite** ការឃ្លានអាហារ

**apply** ដាក់, លាប, រុំ

**arachnida** អដ្ឋបាទិសត្វ

**arachnoid** អដ្ឋបាទិក, ដូចសំណាញ់ពីងពាង, ស្រទាប់ស្តើងៗនៅចន្លោះស្រោមរុំខួរក្បាល និងខួរឆ្អឹងខ្នង

**arterial blood gas (ABG)** ជាតិឧស្ម័នតាមសរសៃឈាម ឬក៏ឧស្ម័នឈាម

**arteriogram** ការពិនិត្យមើលរូបភាពសរសៃឈាមក្រហម(តូច)

**arteriosclerosis** ការធ្វើឲ្យបំពង់សរសៃឈាមក្រហមក្រាស់ ឬរឹង

**artery** សរសៃឈាមក្រហម (តូច)

**artery forcep** ប្រដាប់កៀបសរសៃឈាម កុំឲ្យឈាមហូរចេញ នៅពេលវះកាត់

**arthritis** ជំងឺចុកសន្លាក់ឆ្អឹង

**artificial** សិប្បនិម្មិត (ការក្លែងក្លាយ ឬខុសពីធម្មជាតិ)

**ascites** ការប្រមូលទឹកនៅក្នុងពោះ

**asepsis** ការស្អាត, គ្មានមេរោគសោះ

**asphyxia** ការគ្រោះថ្នាក់ដោយថប់ខ្យល់

**aspirate** បូមយកទឹកឬឈាម, ដកដង្ហើម

**asthma** ជំងឺហឺត

**astringen** ដែលធ្វើឲ្យជាលិការួញ ឬស្វិត, ដែលអាចទប់ឈាម, ភ្នាក់ងារមានឥទ្ធិពលធ្វើឲ្យជាលិការួញឬស្វិត ឬអាចឃាត់ឈាមបាន

**ataxia** អសមត្ថភាពសំរបសំរួលសកម្មភាពសាច់ដុំ នៅពេលមានចលនាឥតបង្ខំ, វិបរិតសរសៃប្រសាទ

**atlas** ឆ្អឹងខ្នងនៃកង់ទីមួយ

**atopic dermatitis** រោគរមាស់រលាកស្បែក ចំឡែក (ដោយរោគប្រតិកម្មអង្គបដិបក្ខប្រាណ តាមពូជ)

**atopy** រោគប្រតិកម្មអង្គបដិបក្ខប្រាណតាមពូជ (មាន លក្ខណៈរោគដូចជា ហឺត, គ្រុនក្តៅ, ឬផ្តួត)

**attention deficit disorder** ឱនភាពខាងការ ប្រុងស្មារតី

**atypical** ដែលប្លែកពីធម្មតា

**aura** អាការៈ

**aural** នៃត្រចៀក

**auricle** ទងត្រចៀក, ភាគខាងលើនៃបេះដូង

**autism** មនោវិកំត (ការរវើរវាយនិងភាន់វិញ្ញាណ)

**autistic disorder** វិកលមនោវិកំត (ដំណើរភ្លាត់ ខុសឬភាន់វិញ្ញាណ តាំងពីនៅទារកឬតាំងពីនៅតូច)

**autoclave** ប្រដាប់រំងាប់មេរោគ ដែលចំហុយ ដោយសំពាធ

**automatic nervous system** ប្រព័ន្ធនៃសរសៃ វិញ្ញាណស្វ័យភាព (ដែលត្រួតពិនិត្យសរីរាង្គខាងក្នុង ដោយខ្លួនឯង ឧទាហរណ៍ : ការរត់ឈាម, ការ រំលាយអាហារ, ការដកដង្ហើម) មកពីពាក្យ "sympathetic nervous system"

**autonomic nervous system** នៃប្រព័ន្ធសរសៃ ប្រសាទស្វ័យភាព (ដែលត្រួតពិនិត្យសរីរាង្គខាងក្នុង ដោយខ្លួនឯង ឧទាហរណ៍ : ការរត់ឈាម, ការរំលាយអាហារ, ការដកដង្ហើម)

**avitaminosis** ជំងឺដែលកើតមកពីការខ្វះជាតិ វីតាមីន

**axilla** ក្លៀក

**axis** ស្នូល, ឆ្អឹងខ្នងកង់ទីពីរ, ឆ្អឹងខ្នង

**B.C.G** ថ្នាំការពារជំងឺរបេង

**B.D (b.i.d)** មួយថ្ងៃពីរដង

**B.M (bowel movement)** ការបត់ជើងធំ, ការបន្ទោរលាមក

**B.P (Blood pressure)** សំពាធឈាម, { បារ. តង់ស្យុងឈាម }

**B.S.R (blood sugar ratio)** ការពិសេធន៍ឈាម ដើម្បីឲ្យដឹងកំរិតជាតិស្ករក្នុងឈាម

**B.U.N (blood uria nitrogent)** ការពិសោធន៍ ឈាមម្យ៉ាង ដើម្បីឲ្យដឹងថាតើវក្កំដើរល្អ ឬមិនល្អ

**bacillus** បាក់តេរីមានរាងត្រង់ដូចចង្កឹះ ឬកោង

**back rest** បង្អែកកំណល់ខ្នង (ឲ្យអង្គុយស្រួល)

**bacteria** មេរោគបាក់តេរី

**bactericidal** ដែលសំឡាប់មេរោគបាក់តេរី

**balkan frame** ដែកដាក់លើគ្រែ សំរាប់ព្យួរ ឧបករណ៍ទាញឆ្អឹងឲ្យត្រង់ឡើងវិញ

**bandage** រុំ, រុំរបួស, ប្រដាប់រុំរបួស, ប៉ង់ស៊ីម៉ង់

**barium** ថ្នាំបញ្ចូលតាមមាត់ឬបាត មុននឹងពិនិត្យ មើលប្រព័ន្ធរំលាយអាហារ ដោយប្រើរស្មីអិក្ស

**bed rest** សំរាកសំរាន្តឲ្យបានច្រើន

**bed sore** ដំបៅ ឬការរលួយសាច់ ដោយព្រោះការ សំរាន្តមិនប្រែខ្លួន

**bedside monitor** ប្រដាប់ពិនិត្យគយគន់ នៅនឹងគ្រែសំរាន្ត

**benefit** អត្ថប្រយោជន៍ (អ្វីៗដែលមានប្រយោជន៍, ប្រយោជន៍ដែលគួរប្រាថ្នា ឬចង់បាន)

**beriberi** រោគស្ពឹក (កើតមកពីខ្វះជាតិវិតាមីន)

**bicep** សាច់ដុំដើមដៃ

**bilateral** ទាំងសងខាង, ទ្វេភាគី

**bile** ទឹកប្រម៉ាត់

**bilirubin** ទឹកប្រម៉ាត់ពណ៌ក្រហម ដែលបណ្តាលឲ្យ ស្បែកនិងភ្នែកឡើងលឿង

**bio** ជីវៈ, ជីវិត, សរីរវិទ្យា

**biologist** អ្នកជីវសាស្ត្រ

**biology** ជីវសាស្ត្រ, (ការសិក្សាដំណើរជីវិត)

**biopsy** ការកាត់យកសាច់បន្តិច ទៅពិនិត្យរកមុខជំងឺ

**bipolar disorder** វិបរិតសរសៃវិញ្ញាណ (ដំណើរប្រែប្រួលនៃសរសៃវិញ្ញាណ ឬប្រសាទ)

**bipolar disorder** វិបត្តិសតិអារម្មណ៍ ដោយមានការខូចចរិត និងការធ្លាក់ទឹកចិត្ត

**black death** អ័ព្ទមរណៈ (ជាជំងឺរាតត្បាតម៉្យាងបានកើតនៅទ្វីបអឺរុប នាសម័យដើម)

**blackwater fewer** រោគគ្រុនទឹកនោមឈាម (គ្រុនទឹកនោមខ្មៅ _ជំងឺនេះអាចស្លាប់បានបើគ្មានឈាមបញ្ចូលឲ្យ)

**bladder** ប្លោកនោម, ប្លោកមូត្រ

**bladder cathether** ទុយោបង្ហូរទឹកនោម

**bland diet** របៀបបរិភោគអាហារដែលទន់ៗស្រួលរំលាយ ជាជាងអាហារដែល ៖ ហឹរ, ញៀន, រឹង, មានសរសៃ, ខ្លាញ់, បន្លែស្រស់, ឬទឹកក្រូច ជាដើម

**bleeding** ការចេញឈាម

**bleeding time** ការពិសោធន៍ឈាម ដើម្បីឲ្យដឹងថាតើឈាមអាចនឹងកកក្នុងរយៈប៉ុន្មាននាទី

**blister** ពងសាច់ (តាមធម្មតាមានទឹកថ្លាៗ)

**blood pressure** ប្រដាប់វាស់សំពាធឈាម

**blood pump** ស្នប់បំពង់បញ្ចូលឈាម (សំរាប់ធ្វើឲ្យឈាមហូរស្រួល)

**blood sugar ratio (B.S.R)** ការពិសេធន៍ឈាម ដើម្បីឲ្យដឹងកំរិតជាតិស្ករក្នុងឈាម

**blood transfusion** ការបញ្ចូលឈាម

**blood uria nitrogent (B.U.N)** ការពិសោធន៍ឈាមម៉្យាង ដើម្បីឲ្យដឹងថាតើវក្កដើរល្អ ឬមិនល្អ

**blur** ព្រិលភ្នែក, ស្រវាំងភ្នែក

**bone** ឆ្អឹង

**borborygmus** គួរពោះ

**bougie** ប្រដាប់សំរាប់រុករក ឬសំរាប់ពង្រីកបំពង់ដំរងនោម _ចុងពោះវៀនធំ

**bowel** ពោះវៀន

**bowel obstruction** ការស្ទះលាមក (ការដែលពោះវៀនមិនដើរល្អ)

**bowel resection and anastomosis** ការវះកាត់យកផ្នែកមួយនៃពោះវៀនចេញ រួចតឡើងវិញ

**bowel wash out (B.W.O)** ការលាងសំអាតពោះវៀន

**Bowman's capsule** សារជាតិខាងក្រៅនៃ "glomerulus"

**brachial** ដែលទាក់ទងនឹងដៃ

**brain** ខួរក្បាល

**breast** ដោះ

**breast pump** ប្រដាប់បូមទឹកដោះចេញ

**breath** ខ្យល់ចេញពីសួត

**breathe** ដកដង្ហើម

**breathless** ដង្ហក់, អស់ដង្ហើម

**breech** រង្វះភ្លៅ

**breech birth** ការកើតកូនច្រាស់ជើង, កូនកើតច្រាស់ជើង

**breech resentation** ការកើតកូនច្រាស់ជើង, កូនកើតច្រាស់ជើង

**broad spectrum** អាចកំចាត់មេរោគច្រើនយ៉ាង (ចំពោះថ្នាំអង់ទីប៊ីយ៉ូទិក)

**bronchia** ទងសួត

**bronchial asthma** សហ័សរោគទងសួត ឬហឺត

**bronchial** នៃទងសួត

**bronchial spasm** ការរួមរួញដីឆាប់រហ័សនៃសួត ដោយអចេតនា

**bronchiectasis** ដំណើរហើមទងសួត

**bronchio-constriction** ដំណើរខ្ទិបទងសួត

**bronchiole** ទងសួតតូច

**bronchitis** ជំងឺរលាកទងសួត

**bronchopneumonia** រោគហើមទងសួត, គ្រុនរលាកទងសួតនិងថង់សួត

**bronchoscope** សួតទស្សន៍, ប្រដាប់ឆ្លុះពិនិត្យមើលទងសួត

**bronchoscopy** ការឆ្លុះពិនិត្យមើលទងសួត

**bronchus** ទងសួត

**bruise** ជាំសាច់
**bulimia nervosa** ការចង់បរិភោគអាហារ មិនចេះឆ្អែតឆ្អន់
**bulla** ពងស្បែក
**buttock** ថ្គាល់ក្ដិត, កំប៉េះគូទ
**caesarean section** ការវះកាត់យកកូន
**calcium** កាល់ស្យូម (ធាតុធ្វើឲ្យឆ្អឹងរឹងមាំ)
**calculus** វត្ថុរឹងដូចថ្ម ដែលកើតឡើងនៅក្នុងសរីរាង្គណាមួយនៃខ្លួន ខុសពីធម្មតា
**calf** កំភួនជើង
**calorie** កាឡូរី, ឯកភាពកំដៅ, ឯកភាពថមពលមកពីអាហារ
**canal** បំពង់ ឬប្រហោងវែង ដែលមាននៅក្នុងខ្លួន
**cancer** រោគមហារីក
**cane** ទំពក់, ប្រដាប់ច្រត់ដើរ
**capillary** សរសៃបង្ហូរឈាម, កេសនាលី
**capillary** កេសនា, សរសៃឈាមតូចៗ
**capsule** គ្រាប់ថ្នាំរាងមូលទ្រវែង, សារជាតិ(ភ្នាស) ស្វិត ដូចជាស្រោមវត្ថុ
**caput** ក្បាល, ប៉ែកខាងលើនៃសរីរាង្គណាមួយ
**carbohydrate** ការបូអ៊ីដ្រាត (អព្យាអង្គធាតុដែលកកើតឡើងដោយសារដំណាំ ឬបន្លែបង្ការ)
**carbon dioxide** ហ្គស្កាបូនិក
**carcinoma** មហារីកសើស្បែក
**cardiac** នៃបេះដូង
**cardiac monitor "The Monitor"** បដាប់ត្រួតមើលបេះដូង ឬ “ប្រដាប់ពិនិត្យគយគន់”
**cardio pulmonary resucitation (CPR)** ការជួយផ្ទុំដង្ហើមបេះដូងឲ្យដើរឡើងវិញ
**caries (dental)** ប្រហោងធ្មេញ
**carotid** សរសៃអាទែរដ៏សំខាន់នៅត្រង់ក
**cartilage** ឆ្អឹងខ្ចី, ឆ្អឹងទន់
**cast** រណបអបឆ្អឹងបាក់, រណបម្នាងសិលារុំទប់ឆ្អឹងបាក់
**cataract** ជំងឺបាយភ្នែក, ជំងឺស្បែកបាំង
**catarrh** ការរលាកស្រទះស្លេស្ម (ជាពិសេសប្រដាប់ដកដង្ហើម ដូចជាទងសួត, បំពង់ក, ច្រមុះ)
**catgut** ជេសដែលធ្វើពីពោះវៀនសត្វ
**catheterize** បញ្ចេញទឹកនោមពីថ្លោកនោម (តាមបំពង់)
**caustic** វត្ថុធាតុប្រើសំរាប់ដុត, ស៊ី, ឬបំផ្លាញជាលិកានៃខ្លួន
**cavity** ប្រអប់, ទីខ្វង, ផត, ប្រហោង(ធ្មេញ)
**cecum** ថ្នក់ផ្នែកខាងដើមនៃពោះវៀនធំ
**cell** កោសិកា
**cellulitis** ការរលាកជាលិកាអសរីរាង្គ (ឧ. ការរលាកស្បែក, សាច់, សាច់ដុំ ដោយមានអាការហើមពណ៌ក្រហម, ឈឺ, ក្ដៅ តែគ្មានបូស)
**cephalalgia** រោគឈឺក្បាល
**cerbellum** ខួរតូច
**cerbrum** ខួរក្បាលធំ
**cerebral** នៃខួរក្បាល, នៃបញ្ញាចិត្ត
**cerebral palsy** ការវិកលចលនាសរសៃញាណជាអចិន្ត្រៃយ៍
**cerebro** ខួរក្បាល
**cerebrospinal** នៃខួរក្បាល និងខួរឆ្អឹងខ្នង
**cerebrospinal fluid** ទឹកស្រោបខួរ
**cerebrovascular** នៃសរសៃឈាមខួរក្បាល
**cervical** នៃក, នៃកស្បូន
**cervix** កស្បូន
**chelelithiasis** ការមានថ្មនៅក្នុងប្រម៉ាត់
**chicken pox** រោគអុតស្វាយ, អុតតូច
**chill** គ្រុនរងា, ស្រៀវស្រាញ
**chills and fewer** គ្រុនរងាស្រៀវស្រាញ
**chlamydate** ដែលមានសំបកឬស្រោម
**chlamydeous** ដែលមានសំបកឬស្រោម
**chlamydia** រោគរលាកប្រស្រីភ្នែក ឬបំបូរន្ធនោម ឬក៏រន្ធយោនី
**chloride** ក្លរីដ

**cholecystectomy** ការវះកាត់យកថង់ប្រម៉ាត់ចេញ
**cholecystitis** ការរលាកថង់បម៉ាត់
**cholecystogram** ការថតរូបថង់ប្រម៉ាត់ដោយកម្ម រស្មីអិក្ស
**cholera** ជម្ងឺអាសន្នរោគ (រោគរាកសាហាវ)
**cholesterol** កូឡិស្ទើរ៉ុល, អង្គធាតុខ្លាញ់ (វត្ថុធាតុខ្លាញ់នៅក្នុងឈាម ហើយបើមានច្រើនពេក វាអាចបង្កើតឲ្យមានជាច្រើនជាន់ ដែលធ្វើឲ្យប្រហោងសរសៃឈាមរួមតូច)
**choroid** ស្រោមគ្រាប់ភ្នែក, កាឡកោស (សរសៃឈាមនៅចន្លោះស្រោមស្ថិតខាងក្រៅរេទីន)
**chronic** រ៉ាំរ៉ៃ, មិនចេះជា, ត្រាំងត្រែង
**circulate** រត់, សាយភាយ (ឈាម, ទឹករងៃ)
**circulatory** នៃការរត់ ឬសាយភាយឈាម
**circumcise** កាត់ចុងស្បែកអង្គជាតចេញ, កាត់ស្បែកលិង្គចោល
**circumcision** ការកាត់ចុងអង្គជាត, ការកាត់ស្បែកលិង្គ
**cirrhosis** រោគថ្លើម
**clamp** អង្កៀ, ប្រដាប់គៀបសរសៃឈាម (កុំឲ្យឈាមហូរ)
**clavicle** ឆ្អឹងដងកាំបិត
**cleft palate** ពិតានមាត់, ក្រអូមមាត់
**clip** ដង្កៀប, ប្រដាប់ខ្ទាស់, ដំបៀត
**clitoris** សិរ, ផ្ដេញ (យោនី)
**clot** កកឈាម
**cloudy** ល្អក់, កករ
**coagulate** បង្កកឈាម, ធ្វើឲ្យឈាមកក
**coccyx** ឆ្អឹងកញ្ចុញតូច
**cochlea** រន្ធត្រចៀក
**colic** ការចុកពោះខ្លាំង, ដែលទាក់ទងនឹងពោះវៀនធំ
**colitis (mucous)** រោគរលាកផ្សាក្នុងពោះវៀនធំ
**collapse** អស់កំឡាំង, ទ្រុឌទ្រោម, អន់ខ្សោយ
**colon** ពោះវៀនធំ
**colonscopy** ការស៊ែកបំពង់ឆ្លុះពិនិត្យពោះវៀនធំ
**colorectal cancer** រោគមហារីកនៃពោះវៀនធំ
**colostomy** ការវះកាត់ឲ្យមានរន្ធតូចជាអចិន្ត្រៃយ៍, ផ្លូវបង្ហូរលាមក
**colostomy bag** ស្បោង ឬថង់ដាក់លាមក
**colporraphy** ការដេរបង្រួមផ្លូវយោនីឲ្យតូច
**coma** សន្លំ, សន្លប់សន្លិន
**compress** ស្បៃ, ក្រណាត់ស្ដើងៗប្រហោងៗ, សង្កត់
**compression boots for circulation** ទ្រនាប់ជើងសង្កត់ឲ្យណែន សំរាប់ការសាយភាយឈាម
**computed tomorgraphy scan (CT Scan)** ការថតឆ្លុះមើលជំរៅរចនាសម្ព័ន្ធជាលិកា (ការថតអិក្សរេម៉្យាង ដែលអនុញ្ញាតឲ្យគ្រូពេទ្យអាចមើលនៅក្នុងពោះបាន)
**conceive** ចាប់មានផ្ទៃពោះ, ចាប់មានគភ៌
**concussion** ការទង្គិចយ៉ាងខ្លាំង, ការញ័ររង្គើខួរក្បាល
**condense** កកជាញើស, ធ្វើចំហាយឲ្យទៅជាទឹក
**confinement** រយៈពេលសំរាលកូន, មិនអាចទៅណាមិនរួច
**confusion** ការវង្វេងស្មារតី, ការច្របូកច្របល់, ព្យាកុលភាព
**congenital** មានមកពីកំណើត
**congestive heart failure** ជំងឺស្វាក់ឈាម, ជំងឺស្ទះបេះដូង
**conical** ដែលមានរាងសាជីមូល, រាងកោណ
**conjunctiva** យុជា, ភ្នាសគ្របកភ្នែកក្នុងប្រស្រីភ្នែក
**conjunctivitis** ជំងឺភ្នែកក្រហម
**conscious** មានស្មារតី, ដឹងខ្លួន
**constipation** ការទល់លាមក
**contagious** ដែលងាយឆ្លងរាលដាល
**contagious disease** ជំងឺដែលងាយឆ្លងរាលដាល
**contraception** ការបង្អត់កំណើតកូន, ការបង្ការកុំឲ្យមានកូន

**contract** បង្រួម(ភ្នែក), រួញ(សាច់ដុំ)
**control** ត្រួតត្រា, ទប់ទល់, បង្ក្រាប, កំរិត
**convalesce** ងើបពីឈឺ, ជាពីជំងឺ
**convave** ខ្វង, ផត
**convenient** ងាយ, ស្រួល, ស្រណុក
**convulsion** ការប្រកាច់
**co-pay** សហ-បង់ប្រាក់
**co-payment** ការសហ-បង់ប្រាក់
**cornea** កញ្ចក់ភ្នែក
**coronary artery** សរសៃឈាមចញ្ចឹមបេះដូង
**coronary thrombus** ការរាំងស្ទះនៃសរសៃឈាមចញ្ចឹមបេះដូង
**cough** ក្អក
**coughing up with blood** ការក្អកធ្លាក់ឈាម
**coverage** ការផ្គត់ផ្គង់ឲ្យ
**covered** ផ្គត់ផ្គង់ឲ្យ
**CPR (cardio pulmonary resucitation)** ការជួយផ្ទុំដង្ហើមបេះដូងឲ្យដើរឡើងវិញ
**cradle cap** ក្អែលកករ, អាចម៍ក្របី
**craniotomy** ការវះចោះឆ្អឹងលលាដ៏ក្បាល
**cranium** លលាដ៏ក្បាល
**crest** កញ្ចុំស្លាប
**crest (of bone)** ទ្រនង់នៃឆ្អឹងអ្វីមួយ
**cricoid cartilage** ឆ្អឹងខ្ចីនៃបំពង់សំឡេង
**cross-match** ការសាកលាយឈាមទាំងពីរមុននឹងបញ្ចូលក្នុងខ្លួន
**croup** រោគឈឺបំពង់កទារក និងកូនក្មេង
**croup** កំប៉េះគូទសេះ
**crutch** ឈើច្រត់, ដែកចង្កត់
**CT scan** ការថតឆ្លុះមើលជំរៅរចនាសម្ព័ន្ធជាលិកា (ការថតអិក្សរេម៉្យាង ដែលអនុញ្ញាតឲ្យគ្រូពេទ្យអាចមើលនៅក្នុងពោះបាន)
**culture and sensitivity** (C&S) ការបណ្ដុះមេរោគពីខ្លួន ដើម្បីរកមុខជំងឺ ឬរកថ្នាំការពារ
**curd** ទឹកដោះខន់(កកតែនៅទន់), ទឹកដោះជូរ,
**cure** អារោគ្យកម្ម, ការធ្វើឲ្យជា, ការសះស្បើយ
**curettage** ការកោសសរីរាង្គ, ការខ្វារសំអាត
**cut down** ការវះស្បែករកសរសៃឈាមដើម្បីបញ្ចូលវត្ថុរាវ
**cyanosis** ស្យាណូស៊ីស, ស្បែកឡើងស្វាយព្រោះខ្វះខ្យល់អុកស៊ីហ្សែនក្នុងឈាម
**cylinder** ស៊ីឡាំង, បំពង់ច្រក, រម្កាការ
**cyst** ពក, ប្លោក, ថង់ភ្នាសបិទជិតដែលមានវត្ថុរាវ (ឬខ្យល់នៅក្នុង)
**cystectomy** ការវះកាត់យកពក ឬប្លោកចេញ
**cystitis** ការរលាកប្លោកនោម
**cysto** មុត្តាស័យ, ពក, ប្លោក, ថង់
**cystocele** កូនលូននៃមុត្តាស័យ
**cystography** ការពិនិត្យមើលផ្លោកនោមដោយប្រើរស្មីអិក្ស
**cystoscope** មុត្តាស័យទស្ស, ការឆ្លុះពិនិត្យមើលមុត្តាស័យ និងបំពង់ទឹកនោម
**cystoscope** ប្រដាប់ពិនិត្យមើលផ្លោកនោមដោយប្រើបំពង់មានពន្លឺភ្លើងនៅខាងចុង
**cystoscopy** ការពិនិត្យមើលផ្លោកនោមដោយប្រើបំពង់មានពន្លឺភ្លើងនៅខាងចុង
**cystostomy** ការវះបើកមុត្តាស័យ
**cyto** កោសិកា
**cytochemical** នៃគីមីកោសិកា
**cytochemistry** គីមីកោសិកា
**cytogenesis** ការបង្កើតជាផលកោសិកា
**cytogenetion** កោសិកាវង្សត្រកូល, កោសិកាគមន៍វិទ្យាសាស្ត្រ
**cytogeny** ផលកោសិកា
**cytology** កោសិកាវិទ្យា
**cytolysin** កោសិការំលាយកម្ម
**cytolytic** ដែលរំលាយកោសិកា
**cytomegalic** មហារីកកោសិកា, កោសិកាដែលរីកធំឡើង

**cytomegalovirus** វីរុសដែលធ្វើឲ្យកោសិកា រីកធំឡើង ឬធ្វើឲ្យឈាមស្ទះ
**cytomegalovirus (CMV)** រោគវីរុស ក្នុងក្រពេញ កោសិកាឈាមមនុស្ស
**cytophagy** ការរំងាប់កោសិកាផ្សេងៗ
**cytophatic** នៃកោសិកាវិភេទ
**cytophometric** នៃកោសិការូបមាត្រ
**cytophometry** កោសិការូបមាត្រ
**cytoplasm** ជំរស្អិត, សារធាតុនៃកោលោហិត
**cytoplasm** ស៊ីតូប្លាស
**cytoplasmic** នៃកោសិកាលោហិត
**cytoplast** កោសិកាលោហិតនិមួយៗ
**cytotaxonomy** វត្តីសរីរៈតាមពួកកោសិកា (ការបែងចែក សរីរៈនៃកោសិកាតាមថ្នាក់, ពួក ឬក្រុម)
**cytotechnologist** អ្នកដែលមានបច្ចេកទេសខាង កោសិកាលោហិត, អ្នកពិនិត្យមើលកោសិកា លោហិតចំឡែក
**D.B.C (differential count)** ការពិសោធន៍ ឈាមដើម្បីរាប់ភាពទីទៃពីគ្នានៃគុល្លិកាស
**dandruff** អង្គែសក់
**deaf** ថ្លង់, ជំឡង់
**deaf-mute** មនុស្សថ្លង់ផងគផង
**death** សេចក្តីស្លាប់, មរណៈភាព
**debililate** ធ្វើឲ្យខ្សោយ, ធ្វើឲ្យល្ហើយកំឡាំង
**debility** ភាពទន់ខ្សោយ, ភាពល្ហើយកំឡាំង
**decidua** អញ្ញាញស្បូន
**deciduous** ដែលរម្ហើ
**defibrillator** ប្រដាប់ស្ទង់ចរន្តបេះដូងដើរ
**deficiency** កង្វះ, ទន់ខ្សោយ, ឱនភាព
**dehydration** កង្វះជាតិទឹកក្នុងខ្លួន
**delirium** រោគមមើមមាយ
**dengue** ជំងឺគ្រុនលោះ
**dental** នៃធ្មេញ (ទន្តិក)
**dentist** ពេទ្យធ្មេញ (ទន្តិកពេទ្យ)
**dentistry** វិជ្ជាពេទ្យធ្មេញ (ទន្តិកពេទ្យវិទ្យា)
**depressant** ភ្នាក់ងារ(ថ្នាំ)បន្ថយដំណើរការ នៃសកម្មភាពរូបកាយ (ថ្នាំសង្កត់សកម្មភាព សរសៃប្រសាទ)
**depression** ការធ្លាក់ទឹកចិត្ត, ការស្រយុត ស្រយុងចិត្ត
**dermatitis** ជំងឺរលាកស្បែក ដែលមានលក្ខណៈ រមាស់, ក្រហម, និងធ្វើឲ្យមានស្នាម
**dermis** ស្បែក, ស្បែកក្នុង
**desicate** ធ្វើឲ្យស្ងួតអស់, ធ្វើឲ្យអស់ជាតិទឹក
**dextrose** ស្ករម្យ៉ាងនៃក្រុមគ្លុយកូស
**diabetes** រោគទឹកនោមផ្អែម (មធុមេហរោគ)
**diabetic** អ្នកកើតរោគទឹកនោមផ្អែម, នៃរោគទឹក នោម
**diarrhea** រាគអាចម៍, ការចុះរាក
**diastole** រយៈកាលបេះដូងពន្លា
**differential count (D.B.C)** ការពិសោធន៍ ឈាមដើម្បីរាប់ភាពទីទៃពីគ្នានៃគុល្លិកាស
**digest** រំលាយអាហារ
**digestion** ការរំលាយអាហារ
**dilatation** ការពង្រីក, ការធ្វើឲ្យរីក
**dilate** ធ្វើឲ្យរីក, ពង្រីក
**diptheria** រោគខាន់ស្លាក់
**disinfect** រំងាប់មេរោគ
**disinfection** ការរំងាប់មេរោគ
**dislocation** ការបាក់គ្រេច, ការភ្លាត់ឆ្អឹង
**disolve** រំលាយ, រលាយ
**disorientation** ការវង្វេងស្មារតី
**dispensary** កន្លែងព្យាបាលនិងចែកថ្នាំ ជាពិសេសចំពោះអ្នកក្រ
**distention** ការហើម ឬតឹង (ដូចជាក្រពះ, ពោះ, ឬពោះវៀន)
**distress** ការឈឺចាប់, ទុក្ខព្រួយ, លំបាក
**diuresis** មានទឹកនោមច្រើនខុសពីធម្មតា
**dizziness** ការវិលមុខ, ការធីងធោង

**dizzy** វិលមុខ, ធីងធោង

**DNA** ភិនភាគនៃសាច់សាលោហិត

**dorsal** ដែលទាក់ទង ឬឋិតនៅជិត ឬនៅខ្នង

**dose** កំរិតថ្នាំត្រូវប្រើ

**douche** ទឹក, ធម្មតាមានថ្នាំ, បាញ់លាងផ្នែកនៃខ្លួន ឬបញ្ចូលតាមសរីរាង្គផ្លូវយោនី

**drop** ដំណក់, បន្តក់

**drug** ឱសថ, ថ្នាំ, គ្រឿងញៀន

**drug reaction** ប្រតិកម្មថ្នាំ

**duodenal** ដែលទាក់ទងផ្នែកដើមនៃពោះវៀនតូច, មានប្រវែងប្រហែល ១២ ម្រាមដៃ

**dura mater** លលាដ៍ខួរក្បាល ឬស្រោមខួរឆ្អឹងខ្នង (គំរបខួរក្បាល)

**durable medical equipment** និរន្តរាយ បរិក្ខារពេទ្យ (ប្រដាប់ប្រដាពេទ្យដែលមិនងាយ អន្តរាយ ឬវិនាស)

**dysentary** រោគរាកមូល, អាមាតិសារ

**dysepsia** ការរលាយអាហារដោយពិបាក

**dyspeptic** ជំងឺចាក់ប្រាស

**dysphagia** ការពិបាកលេប, រោគធុមបាយ

**dysphasia** ការវិកលសំដី

**dysphonia** ការលំបាកនិយាយ

**dyspnea** ការស្ទះដង្ហើម, ការដកដង្ហើមតឹង

**dyspneic** ដែលស្ទះដង្ហើម

**dysthymic** ភាពមិនធម្មតានៃរលកក្នុងខួរក្បាល

**dystrophy** អនិបុណ្យបោសនា, កង្វះអាហារ សំរាប់ចិញ្ចឹមរាងកាយ

**dysuria** ការទល់នោម, ការស្ទះទឹកនោម

**ear drum** ក្រដាសត្រចៀក

**echocardiogram** ការវិនិច្ឆ័យវាស់ស្ទង់រចនា សម្ព័ន្ធនៃចលនាបេះដូង

**eclampsia** ការប្រកាច់ នៅពេលមានផ្ទៃពោះ, សំរាលកូន, ឬនៅពេលឈឺ

**ectopic pregnancy** កូនក្រៅស្បូន (ការលូត លាស់នៃស៊ុតនៅក្នុងប្រមោយ)

**eczema** រោគត្រអក ឬតាអក, រោគសើស្បែក

**edema** ការហើម

**electrocardiogram (ECG)** ការថតចរន្តអគ្គីសនី នៃការកន្ត្រាក់សាច់ដុំបេះដូង

**electrocute** គ្រោះថ្នាក់ខ្សែភ្លើងឆក់

**electroencephalygram (EEG)** ការថតចរន្ត អគ្គីសនីរលកខួរក្បាល

**electrolyte** អេឡិកត្រូលីត, វត្ថុធាតុដែលធ្វើជា ល្បាយចំឡងអគ្គិសនី, វត្ថុធាតុដែលបំបែក ដោយអគ្គិសនី

**elevate** ធ្វើឲ្យខ្ពស់ឡើង, លើកឡើង

**elixer** ល្បាយថ្នាំ ដែលមានថ្នាំ-អាកុល-ស្ករ-និងក្លិន បន្ថិច

**embolism** ការស្ទះសរសៃឈាម (ដោយឈាមកក ឬមានវត្ថុចំឡែកផ្សេងទៀត រាំងផ្លូវឈាម)

**embryo** ភ្រូណា, ទារកក្នុងស្បូន

**emergency services** ការបំរើនៅគ្រាអាសន្ន, កិច្ចការនៅគ្រាអាសន្ន

**emesis** ការក្អួតចង្អោរ

**emotion** វេទនារម្មណ៍ (ការដឹងអារម្មណ៍ថាជាសុខ ឬជាទុក្ខ -ច្រើនសំដៅទៅលើការទុក្ខ)

**emotional disturbances** ដំណើរប្រែប្រួល ខាងវេទនារម្មណ៍

**empyema** ការកខ្ទុះនៅចន្លោះរវាងស្រោមសួត

**emulsifier** ភ្នាក់ងារធ្វើឲ្យវត្ថុរាវពីររលាយចូលគ្នា បាន (ប្រេងនឹងទឹក)

**emulsify** គាបយកប្រេង

**encephalic** នៃខួរក្បាល

**encephalitic** នៃរោគរលាកខួរក្បាល

**encephalitis** រោគរលាកខួរក្បាល

**endoblast** ភ្នាសក្នុងជីវាំណូ, ស្រទាប់ខាងក្នុង ស្បូន

**endocardia** នៃផ្នែកស្រទាប់បេះដូង

**endocarditis** រោគរលាកទ្រនាប់ស្បែកបេះដូង និងសន្ទះបេះដូង

**endocardium** សរសៃក្នុងហទយ, ភ្នាសក្នុងបេះដូង

**endocrine** អន្តោមញ្ញូន, ក្រពេញផលិតសាធាតុខាងក្នុងខ្លួន, ក្រពេញបញ្ចេញអ័រម៉ូន

**endocrine gland** ក្រពេញបញ្ចេញអ័រម៉ូន, ក្រពេញអន្តោមញ្ញូន

**endocrinology** អន្តោមញ្ញូនវិជ្ជា, ការសិក្សាអំពីក្រពេញដែលផលិតសារធាតុក្នុងខ្លួន

**endoderm** ភ្នាសក្នុងជីវ៉ាណូ, ស្រទាប់ខាងក្នុងស្បូន

**endodontic** បណ្តូលធ្មេញ

**endodontics** ទន្តពេទ្យ, ការព្យាបាលខាងរោគបណ្តូលធ្មេញ

**endometriosis** ការមានដាច់អញ្ចាញស្បូនជាដុំៗទៅកន្លែងខុសពីធម្មតា

**endometrium** អញ្ចាញស្បូន

**endotracheal** ឋិតក្នុងបំពង់ក

**endotracheal tube** វ័ម្ពដាក់ក្នុងបំពង់ក

**enema** ការបញ្ចុះលាមក

**entamoeba histolytica** អតិសុខុមប្រាណមានកោសិកាតែមួយ (អាចមាននៅក្នុងពោះវៀន, ថ្លើម, សួត, ឬខួរក្បាល)

**enteritis** ជំងឺរលាកពោះវៀន

**entoderm** ភ្នោសក្នុងជីវ៉ាណូ, ស្រទាប់ខាងក្នុងស្បូន

**enucleation** ការវះយកដុំសាច់ ឬវត្ថុផ្សេងទៀតដោយយកទាំងមូលចេញ

**enzyme** អង់ស៊ីម, សារធាតុដែលបណ្តាលឲ្យមានឬជំរុញឲ្យប្រតិកម្មអ្វីមួយ

**epidermis** ស្រើស្បែក

**epiglottis** កន្ទើត, សន្ទះខ្យល់

**epilepsy** ជំងឺស្កន់ ឬឆ្កួតជ្រូក

**episiotomy** ការវះបន្តផ្នែកក្រោមយោនី (នៅពេលសំរាលកូនមិនរួច ដើម្បីការពារកុំឲ្យរហែកទ្វារយោនី)

**epitaxis** ការចេញឈាមតាមច្រមុះ, ឈាមច្រមុះ

**erythrocyte** កោសិកាឈាមក្រហម

**erythropoisis** ការផលិតកោសិកាឈាមក្រហម

**esophagoscopy** ការឆ្លុះពិនិត្យមើលក្នុងបំពង់អាហារ (ដោយប្រដាប់ពិនិត្យមានអំពូលភ្លើង)

**esophagus** បំពង់អាហារ

**eustachian tube** រន្ធខ្យល់, ភ្ជាប់ផ្នែកត្រចៀកកណ្តាល

**eviscerate** បញ្ចេញ, ធ្លាយសរីរាង្គនៅក្នុងពោះ

**excision** ការកាត់ផ្នែកមួយនៃសរីរាង្គចេញ

**excretion** សំណល់ពីខ្លួន, លាមក, អាចម៍

**expectorant** ថ្នាំជួយបញ្ចេញស្លេស្ម (ពីសួតនិងបំពង់ខ្យល់)

**extended critical care unit** ប៉ែកបន្តថែរក្សាអ្នកជំងឺធុនដាប

**extraction** ការយកចេញ, ការដកធ្មេញ

**faint** ការសន្លប់ដោយខ្វះឈាមក្នុងខួរក្បាល, ខ្សោយកំឡាំងល្ហិតល្ហៃ

**fallopian tube** ប្រមោយ ឬដៃស្បូន

**fascia** បន្ទះជាលិកាមានភាពជាសរសៃដែលគ្រង, ទ្រ, និងចងសរីរាង្គខាងក្នុង

**fasting** ការតមអាហារ

**feces** លាមក

**feeble** ខ្សោយ, ថយកំឡាំង

**femure** ឆ្អឹងភ្លៅ

**fertility** ឧទរភាព (ភាពអាចមានផ្ទៃពោះ)

**fetus** ទារកក្នុងឧទរ, កូនង៉ែតមិនទាន់កើត

**fibrin** សារធាតុនៅក្នុងឈាមកក

**fibroid** ដុំសាច់ដែលមានជាលិកាជាសរសៃភ្ជាប់តាមធម្មតានៅក្នុងស្បូន (មិនមែនមហារីកទេ), ដែលមាន ឬដូចជាសរសៃភ្ជាប់តូចៗ

**fibula** ឆ្អឹងតូចនៃកំភួនជើង, ឆ្អឹងស្មងជើង

**filaria** ព្រូនម្យ៉ាងមានរាងដូចអំបោះ

**filariasis** ជំងឺរ៉ាំរ៉ៃបណ្តាលមកពីព្រូនរាងដូចអំបោះ

**first aid** ការជួយសង្គ្រោះជាបន្ទាន់

**fissure** ចង្អូរតូចៗនៅខួរ, ដំបៅដោយបំរែះ
**fistula** ដំបៅស៊ីរូង (ដែលញយៗវាទាក់ទងស្បែក និងសរីរាង្គ), ប្លូសក្លាយ
**flaccid** ភាពទន់, ភាពរលា (សាច់ដុំ)
**flatulence** ឆ្អល់ពោះ ឬហើមពោះ
**flatus** ផោម
**flatus tube** បំពង់បន្តឲ្យចេញផោម
**flea** ចៃឆ្កែ
**flow measurement** វង្វាស់វង្វាល់ការហូរ
**fluke** ព្រូនមានរាងដូចស្លឹកឈើ
**flush** បង្ហូរនិងរាយសាយភ្លាមៗ, ក្រហមមុខឬក
**foley catheter** ផ្លោកត្រងទឹកនោម
**fontanel** បង្ហើយក្បាល
**Food and Drug Administration** នាយកដ្ឋានភោជនភណ្ឌ និងឱសថូបករណ៍
**forcep** ដង្កៀប, ដង្កាប់សំរាប់ទាញឬចាប់
**forehead** ថ្ងាស
**foreign body** វត្ថុចំឡែកនៅក្នុងខ្លួន
**fracture** បាក់ឆ្អឹង
**fundus** ផ្នែកប្រឈមក្នុងសរីរាង្គមួយ (បាតស្បូន)
**fungicide** ថ្នាំសំឡាប់រោគផ្សិត
**fungus** រោគផ្សិត (មានផ្សិតតូចៗធ្វើឲ្យឈឺនៅខ្លួន)
**galactosemia** លក្ខណៈជំងឺខ្វះជាតិស្ករពីកំណើត ដែលមិនអាចប្តូរជាតិហ្គាឡាក់តូ(ស្ករ) ទៅជាគ្លុយកូ
**gallbladder** ប្រម៉ាត់
**ganglion** មជ្ឈមណ្ឌលប្រសាទ, ដុំសាច់តូច រឹងកើតនៅស្រោមសរសៃពួរ ឬសន្ទាក់
**gangrene** ដំបៅរលួយ (ដោយកង្វះឈាមរត់ ឬដោយសារមុខរបួសមិនស្អាត)
**gargle** ខ្ពុរមាត់
**gastrectomy** ការវះកាត់យកក្រពះ ឬផ្នែកខ្លះ នៃក្រពេញ
**gastric** នៃក្រពះ
**gastric lavage** ការលាងក្រពះ
**gastritis** ជំងឺរលាកក្រពះ
**gastro-enteritis** ជំងឺរលាកក្រពះនិងពោះវៀន
**gauze** ស្បៃ
**genital** ប្រដាប់បន្តពូជ, នៃអង្គជាត
**genito-urinary** ប្រដាប់បន្តពូជ និងប្រដាប់នោម
**germ** មេរោគ
**germicide** ថ្នាំសំឡាប់មេរោគ, ការសំឡាប់មេរោគ
**gingivitis** ជំងឺរលាកអញ្ចាញធ្មេញ
**gland** គ្រន្ថី, ក្រពេញ
**glaucoma** ជំងឺភ្នែកដែលតង់ស្យុងភ្នែកលើសពីធម្មតា
**glomerulus** ក្រុមសរសៃឈាមតូចៗ (ឋិតនៅវ័ក្ក)
**glossitis** ជ្រាំងអណ្តាត
**glucose** គ្លុយកូស, ជាតិស្ករ
**goiter** ជំងឺពកក
**gonnorrhea** រោគប្រមេះ
**gonococcus** មេរោគប្រមេះ
**graft** បន្ទះស្បែកយកពីកន្លែងមួយទៅប៉ះកន្លែង មួយទៀតនៃខ្លួន, រៀបចំជាថ្មីនៅកន្លែងខ្វះ
**gram negative** អាចសាកពណ៌វិញ
**gram positive** ពុំអាចសាកពណ៌វិញ
**grandmal seisure** ការប្រកាច់ខ្លាំងនៃជំងឺឆ្កួតជ្រូក
**granulation** កន្ទួលសាច់តូចៗ កើតលើផ្ទៃដំបៅ
**gravida** ស្ត្រីមានផ្ទៃពោះ (គេនិយាយពាក្យនេះ ព្រមគ្នាជាមួយចំនួនពេលមានផ្ទៃពោះ)
**gravity** ទំងន់, ទំនាញផែនដី, ភាពធ្ងន់ធ្ងរ, ដំណំ
**groin** ក្រលៀន
**gum** ជើងធ្មេញ, អញ្ចាញធ្មេញ
**gyncology** វិជ្ជាពេទ្យខាងសរីរៈ, ពេទ្យរោគស្ត្រី
**haemophilus influenza type b** រោគផ្តាសាយធ្វើឲ្យរលាកបំពង់ក
**hallucination** ការមមើមមាយ
**health care** សុខាភិបាល (ការថែរក្សាឬគ្រប់គ្រង, ការទំនុកបំរុងឲ្យបានសុខ)
**health practicioner** អ្នកវេជ្ជជីវៈ (អ្នកប្រកបរបរខាងព្យាបាលអ្នកជំងឺ)

**heart burn** ការឆ្អល់ចុងដង្ហើម (ដោយទឹកក្រពះចូលក្នុងបំពង់អាហារ)
**heart rate** ល្បឿនបេះដូង
**heart rhythm** ចង្វាក់បេះដូង
**hematemesis** ការក្អួតធ្លាក់ឈាម
**hematic** នៃកោសិកាឈាមក្រហម
**hemato** ឈាម, លោហិត
**hematoblast** ឈាមខ្ចី, ឈាមមិនទាន់ក្រហម
**hematogenesis** ការបង្កបង្កើតឈាម
**hematology** ឈាមវិទ្យា
**hematolysis** ការវិភាគឈាម
**hematoma** ជាំសាច់, ហើមសាច់មានបែកឈាមក្នុងស្បែក
**hematopoiesis** ដំណើរបង្កបង្កើតឈាម
**hematosis** ដំណើរធ្លាក់ឈាម
**hematuria** នោមឈាម, ទឹកនោមមានឈាម
**hemeralopia** រោគងងឹតភ្នែកពេលថ្ងៃ, រោគស្រវាំងភ្នែក
**hemeralopic** ខ្វាក់មាន់
**hemialgia** ការឈឺពាក់កណ្តាលខ្លួន
**hemianopsia** ភ្នែកខ្វាក់ពាក់កណ្តាលប្រស្រីភ្នែក
**hemicrania** រោគឈឺមួយចំហៀងក្បាល
**hemiplegia** រោគស្លាប់ពាក់កណ្តាលខ្លួន
**hemiplegia** ការស្លាប់មួយចំហៀងខ្លួន
**hemocyte** កោសិកាក្រហម
**hemoglobin** ជាតិក្រហមនៃឈាម
**hemoglobinuria** ការធ្លាក់ឈាមតាមទឹកនោម
**hemoleukocyte** កោសិកាឈាមស
**hemophilia** រោគមិនខន់ឈាម
**hemophiliac** អ្នកកើតរោគមិនខន់ឈាម
**hemophobia** ការខ្លាចឈាម
**hemoptysis** ក្អកធ្លាក់ឈាម, ការធ្លាក់ឈាមតាមមាត់
**hemorrhage** ការធ្លាក់ឈាម, ការចេញឈាម
**hemorrhage fever** គ្រុនពោះវៀន
**hemorrhoid** ឫសដូងបាត
**hemostasis** ការឃាត់ឈាម
**heparin-lock** ការស៊ិកធាតុម្យ៉ាងដើម្បីកុំឲ្យកកឈាម
**hepatic** នៃថ្លើម
**hepatite** ថ្លើម
**hepatitis** រោគហើមថ្លើម
**hepatocellular** ការពិនិត្យមើលរចនាកោសិកា
**hepatoma** ការដុះសាច់នៅថ្លើម, មហារីកថ្លើម
**hernia** រោគក្លូន, ក្លូនលូន
**herniorrhaphy** ការវះរោគក្លូន
**herpes** ពងតូចៗដំរៀបជិតៗគ្នាមានទឹកថ្លា បន្ទាប់មកក្លាយជាល្អក់ រួចរីងស្ងួតដោយទុកក្រមរ
**herpes zoster** រើមខ្សាច់ ឬរើមចង្កោម (ច្រើនកើតនៅចំហៀងខ្លួនតាមសរសៃប្រសាទ បណ្តាលមកពីមេរោគវីរុសហឺព)
**hiccough** ក្អើក
**hiccup** ក្អើក
**histamine** វត្ថុធាតុមានក្នុងខ្លួន ដែលធ្វើឲ្យមានប្រតិកម្ម
**HIV** កង្វះភាពស៊ាំឲ្យមនុស្សធ្លននឹងមេរោគវីរុស
**hive** ផ្លូត
**hives** ផ្លូតៗជាច្រើននៅលើស្បែក
**Hodgkin's disease** ជំងឺម្យ៉ាងនៃក្រពេញទឹករងៃ
**home for the aged** លំនៅជរាជនាស្រ័យ (ទីអាស្រ័យនៅសំរាប់ជនជរា)
**homeless** អនាថជន, ជនអនាល័យ, មនុស្សគ្មានលំនៅ
**hormone** អ័រម៉ូន
**hospice care** គិលានសង្គ្រោះជនមានជំងឺដែលមុខតែនឹងស្លាប់ (ការជួយជីវិតឬថែទាំអ្នកជំងឺដែលឈឺគង់តែនឹងស្លាប់)
**human immunodeficiency virus (HIV)** កង្វះភាពស៊ាំឲ្យមនុស្សធ្លននឹងមេរោគវីរុស

**human T cell lymphotropic (HTLV)** មេរោគវីរុសក្នុងថ្លោកនោមមនុស្ស

**humerus** ឆ្អឹងដើមដៃ

**hydatiform mole** ដុំក្រាបដូចផ្លែទំពាំងបាយជូរ លូតលាស់ក្នុងស្បូន (កើតពីភ្នាសស៊ុត)

**hydration** ការផ្សំនឹងទឹក

**hydrocephalic** កសំបូរណ៍ទឹកច្រើនក្នុងខួរក្បាល (ធ្វើឲ្យក្បាលធំ)

**hyoglycemia** កំរិតជាតិស្ករតិចជាងពីធម្មតា

**hyperalimentatio** ការបញ្ចូកចំណីអាហារ ចូលតាមសរសៃឈាម

**hyperglycemia** កំរិតស្ករក្នុងឈាមលើសពីធម្មតា

**hyperpyexia** កំដៅខ្លួនលើសពីធម្មតា

**hypertension** ដំណើរតឹងសរសៃដោយឡើងឈាម

**hypertonic** ដែលមានកំហាប់ច្រើន, ដែលមានតង់ស្យុងច្រើន, ដែលមានសាច់ដុំច្រើន

**hypodermis** នៅខាងក្រោមស្បែក

**hypotension** ដំណើរធូរសរសៃឈាម, ការចុះសំពាធឈាម

**hypotensive** ដែលទាក់ទងនឹងតង់ស្យុង (ខ្សោយជាងធម្មតា ជាពិសេសខ្សោយសំពាធឈាម)

**hypotonia** ការមិនសូវមានកំហាប់, ខ្សោយសាច់ដុំ

**hypotonic** ដែលមានកំហាប់តិច, ដែលមានតង់ស្យុងតិច, ដែលមានសាច់ដុំតិច

**hysterectomy** ការវះកាត់ស្បូនចេញ

**hysteria** ការឡប់សតិ, ការជ្រួលច្របាលចិត្តខ្លាំងពេក

**icterus** រោគលឿង

**ICU (intensive care unit)** ប៉ែកថែរក្សាអ្នកជំងឺដុនដាប

**ileitis** ជំងឺរលាកផ្នែកនៃពោះវៀនតូច

**ileostomy** ការចោះរន្ធ នៅផ្នែកនៃពោះវៀនតូច (មកពីពោះ)

**ileum** ផ្នែកពោះវៀន, ចុងពោះវៀន

**ileus** ការខូច ដោយការរារាំងពោះវៀន

**immunity** ភាពស៊ាំនឹងរោគ

**immunization** ការចាក់ថ្នាំឲ្យស៊ាំនឹងរោគ

**immunize** ចាក់ថ្នាំឲ្យស៊ាំនឹងរោគ

**impetigo** ជំងឺរលាកស្បែក (ធម្មតាក្នុងកូនក្មេង)

**implant** បណ្ដុះបន្សាំ (ការយកជាលិកាឬសរីរាង្គពីអ្នកផ្សេងមកប្រើឲ្យស៊ាំថ្មីក ជារបស់ខ្លួន)

**incision** កន្ទែងវះ, ថ្នេរ

**incontinence** ការបន្ទោរបង់លាមក ឬទឹកនោម ដោយមិនដឹងខ្លួន (មិនអាចគ្រួតត្រាខ្លួនបាន)

**incubator** ឧបករណ៍មានកំដៅសំរាប់ដាក់កូនង៉ែត កើតមិនគ្រប់ខែឲ្យគេង, ឧបករណ៍មានកំដៅសំរាប់បណ្ដុះបាក់តេរី

**incurable** ដែលមិនអាចជាបាន

**indigestion** ការពិបាក ឬមិនអាចរំលាយអាហារ, ជំងឺចាក់ប្រាស

**indwelling catheter** បំពង់ដែលបញ្ចូលទុកក្នុងថ្លោកនោម

**inertia** ភាពមិនកំរើក, ទំលាប់នៅស្ងៀម, និចលភាព

**infant** កូនខ្ចី, ទារក

**infect** ចំឡងរោគ, បង្ករោគ

**infection** ជំងឺបង្កដោយមេរោគ, ដំបៅក្លាយ, អាពាធ

**infectious** ដែលបង្កដោយមេរោគ, ដែលឆ្លង

**inferior vena cava** សរសៃឈាមខ្មៅធំ នៅខាងក្រោមបេះដូង

**infertility** អសមត្ថភាពមានឧទរ, ភាពពុំអាចមានផ្ទៃពោះបាន

**inflame** ហើមរលាក, ឡើងក្រហម

**inflammation** ការហើយមរលាក, ការឡើងក្រហម

**influenza** ជំងឺគ្រុនផ្ដាសាយធំ

**infract** កន្លែងជាលិកាងាប់ (ដោយការរាំងដំណើរឈាមទៅកន្លែងនោះ)

**ingest** ញ៉ាំអាហារ, លេបចូល

**ingestion** ការញ៉ាំអាហារ, ការលេបចូល

**inhale** ដកដង្ហើមចូល, ស្រូបចូលតាមច្រមុះ
**inhibit** បង្សាត់ដំណើរ, បញ្ឈប់មុខងារនៃសរីរាង្គ
**injection** ការចាក់ថ្នាំ
**injury** ការមានរបួស, ការខូចបង់
**inlet** ផ្លូវចូលទៅក្នុងថត, ច្រកចូល
**inoperatable** ពុំអាចវះកាត់កើត ដោយយល់ថា ពុំអាចនឹងជា ឬនាំឲ្យមានគ្រោះថ្នាក់
**insecticide** ថ្នាំសំឡាប់ ឬបំផ្លាញសត្វល្អិត
**insomnia** រោគដេកមិនលក់
**inspiration** ការដកដង្ហើមចូល
**intake** ខ្លួនបានទទួល, ចំនួនម្ហូបឬទឹកចូលក្នុងខ្លួន មួយរយៈកាល
**intensive care unit (ICU)** ប៉ែកថែរក្សាអ្នកជំងឺធុនធាប, ផ្នែកថែទាំអ្នកជំងឺយ៉ាងល្អិតល្អន់
**intercellular** ដែលនៅចន្លោះកោសិកា
**intercostal** ដែលនៅចន្លោះឆ្អឹងជំនី
**intercourse** ការរួមដំណេក, ការរួមសង្វាស
**intermittant** ដែលរអាក់រអួល, ដែលដើរឈប់ៗ
